# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ ១២៩១.ព្រទ.កយ-២០០២

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ជម្រាបមក</u>

**លោកប្រធានតុលាការខេត្ត ក្រុង**
**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**<u>កម្មវត្ថុ</u>:** អំពីការអនុវត្តន៍ការងារបន្ធូរបន្ថយទោស លើកលែងទោស និងសំណើសុំដោះលែងទណ្ឌិតដែលមានផ្ទុកមេរោគអេដស៍ ឬកើតជម្ងឺអេដស៍ (AIDS) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមរំលឹកអស់លោកប្រធានតុលាការ នឹងកព្រះរាជអាជ្ញាថា មកដល់ថ្ងៃនេះចំនួនទណ្ឌិតដែលបានស្នើសុំបន្ធូរបន្ថយទោស នឹងលើកលែងទោយមានចំនួនកើនច្រើនឡើងជាលំដាប់ ក្រសួងបានជួបប្រទះការលំបាកស្មុគ្រស្មាញមួយចំនួនទាក់ទងនឹងពេលវេលា និងភាពខ្វះខាតនៃសំណុំឯកសារដែលបញ្ជូនមកពីតុលាការ និងអយ្យការខេត្ត-ក្រុង ។

ដើម្បីរៀបចំបែបបទធ្វើរបាយការណ៍ និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការលើកលែងទោសបន្ធូរបន្ថយទោសដល់ទណ្ឌិតដាក់ថ្វាយព្រះមហាក្សត្រទ្រង់ព្រះតម្រិះ និងឡាយព្រះហស្តលេខាឱ្យបានទាន់ពេលវេលាខ្ញុំសូមលោកប្រធាន និងលោកព្រះរាជអាជ្ញាយកចិត្តទុកដាក់អនុវត្តនូវវិធានសំខាន់ៗដូចតទៅ៖

១-សំណុំឯកសារស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសត្រូវចាត់បញ្ជូនឱ្យបានទាន់ពេលវេលាតាមកាលកំណត់ដូចខាងក្រោមនេះ៖

ក/សម្រាប់ឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យពិសាខបូជា ត្រូវលៃលកធ្វើយ៉ាងណាចាត់បញ្ជូនសំណុំឯកសារឱ្យបានមកដល់ទីស្តីការក្រសួងយុត្តិធម៌យ៉ាងតិចមួយខែមុនថ្ងៃទី១៣ ខែមេសា នៃឆ្នាំ។

ខ/សម្រាប់ឱកាសបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ និងបុណ្យតាំងតុ អុំទូកអកអំបុកសំពះព្រះខែត្រូវលៃលកធ្វើយ៉ាងណា ចាត់បញ្ជូនសំណុំឯកសារឱ្យមកដល់ទីស្តីការក្រសួងយ៉ាងហោចណាស់ពីរខែមុនថ្ងៃទី៣០ ខែតុលា នៃឆ្នាំ ។

២-គ្រប់សម្រង់ ឬសេចក្តីចម្លងសាលក្រមព្រហ្មទណ្ឌ ដែលភ្ជាប់មកជាមួយត្រូវមានចំណារអំពីអានុភាពរបស់វា (ការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា) ។

៣-សម្រង់សាលក្រម ឬសេចក្តីចម្លងសាលក្រមទាំងនេះ ត្រូវមានលក្ខណៈអាចមើលឃើញច្បាស់ ឬអាចអានបាន ។

៤-ពិនិត្យលទ្ធភាពដែលអាចបន្ធូរបន្ថយ ឬលើកលែងទោសបានដោយផ្អែកតាមលក្ខខ័ណ្ឌដែលមានកំណត់ក្នុងក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០-០៦-៨៨ មុននឹងផ្ញើមកក្រសួងយុត្តិធម៌ ។

**<u>កត់សម្គាល់ ៖</u>**

ក/ទណ្ឌិតម្នាក់អាចទទួលបានការបន្ធូរបន្ថយទោស ឬលើកលែងទោសបានតែម្តងគត់ក្នុងឱកាសនៃពិធីបុណ្យទាំងបីលើកនៃឆ្នាំនិមួយៗ ។

ខ/សំណុំឯកសារស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសទាំងឡាយណាដែលបានមកដល់ទីស្តីការក្រសួងដោយយឺតយ៉ាវ មិនត្រឹមត្រូវតាមកាលវេលាដូចបានកំណត់ក្នុងចំណុច១ និងមិនគ្រប់លក្ខណៈសម្បត្តិដូចបានកំណត់ក្នុងចំណុច២-៣ និង ៤ ខាងលើ ក្រសួងនឹងមិនទទួលពិនិត្យចាត់ការតាមសំណើឡើយ ។ ដោយឡែកសំណើសុំដោះលែងទណ្ឌិតដែលមានផ្ទុកមេរោគអេដស៍ ឬកើតជម្ងឺអេដស៍តម្រូវឱ្យមានការធ្វើអធិការកិច្ចវាយតម្លៃនិងមានការឯកភាពពីអគ្គាធិការដ្ឋានកិច្ចការតុលាការរបស់ក្រសួងយុត្តិធម៌ជាមុនសិន ដើម្បីបង្ការនិងជៀសវាងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗដល់ស្ថានភាពសង្គមដែលប្រព្រឹត្តដោយទណ្ឌិតប្រភេទនេះ ក្រោយពីពួកគេត្រូវបានដោះលែងពីពន្ធនាគារទៅនោះ ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា អនុវត្តតាមការណែនាំនេះឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីការពារផលប្រយោជន៍ច្បាប់តទៅ ។

សូមលោកប្រធាន និងលោកព្រះរាជអាជ្ញា ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**នាង ស៊ីផុន**

ចម្លងជូន

-សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-ដើម្បីជូនជ្រាប